ភ្នំពេញ, ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២

# សេចក្តីថ្លែងការណ៍ ស្តីពី ការរៀបចំជ្រើសរើសគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា(**ខុមហ្វ្រែល**) គណៈកម្មាធិការអព្យាក្រិត្យ និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា(**និកហ្វិច**) អង្គការប្រជាធិបតេយ្យ និងសិទ្ធិមនុស្សក្នុងប្រតិបត្តិការ(**ដ្រាក**) និងអង្គការសម្ព័ន្ធដើម្បីសុចរិតភាព គណនេយ្យភាព និងតម្លាភាព(CISA) យល់ឃើញថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(**គ.ជ.ប**) ជាកត្តាកំណត់ក្នុងការរៀបចំការបោះឆ្នោតមួយដោយសេរី និងយុត្តិធម៌។ ជាគោលការណ៍ គ.ជ.ប **មួយមានលក្ខណៈឯករាជ្យ ជាពិសេសសមាសភាព និងការអនុវត្តន៍តួនាទីត្រូវតែ អព្យាក្រិត្យពីរាជរដ្ឋាភិបាល និងគណបក្សនយោបាយ**។ ប៉ុន្តែដោយឡែកនៅកម្ពុជា ច្បាប់ និងការអនុវត្តន៍ ស្តីពីការបង្កើត គ.ជ.ប មិនបានផ្តល់នូវតម្លាភាពពេញលេញក្នុងការជ្រើសរើសសមាសភាព គ.ជ.ប និងការមិនជឿជាក់របស់គណបក្សនយោបាយថា មានមនុស្ស "អព្យាក្រិត្យ"។

គណៈកម្មាធិការខុមហ្វ្រែល គណៈកម្មាធិការនិកហ្វិច អង្គការដ្រាក និងអង្គការសម្ព័ន្ធCISA គាំទ្រចំពោះការរៀបចំកិច្ចពិភាក្សាដោយស្រុះស្រួលគ្នា ក្នុងចំណោមគណបក្សនយោបាយសំខាន់ៗមានអាសនៈនៅក្នុងរដ្ឋសភា ដើម្បីជ្រើសរើស និងកំណត់សមាសភាព គ.ជ.ប **គ្រប់លំដាប់ថ្នាក់ពីថ្នាក់ជាតិ រហូតដល់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត** ដែលត្រូវមានតំណាង និងការទុកចិត្តពេញលេញពីគណបក្សនយោបាយ មានអាសនៈក្នុងរដ្ឋសភា។

***ព័ត៌មានបន្ថែមសូមទំនាក់ទំនង***

១. លោក **ធន សារាយ** ប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល និងជាប្រធានសមាគមអាដហុក / លេខទូរស័ព្ទ ០១៦ ៤៤០ ០៤៤

២. បណ្ឌិត **ហង្ស ពុទ្ធា** នាយកប្រតិបត្តិអង្គការនិកហ្វិច / លេខទូរស័ព្ទ ០១២ ៩៥៩ ៦៦៦

៣. លោក **គល់ បញ្ញា** នាយកប្រតិបត្តិខុមហ្វ្រែល / លេខទូរស័ព្ទ ០១២ ៩៤២ ០១៧

៤. លោក **ឡុង បូរិន្ទ** អ្នកសម្របសម្រួល CISA / លេខទូរស័ព្ទ ០១២ ៩៨៧ ១៥៨

៥. បណ្ឌិត **ហ្វ្រង់ស្វ័រ អ៊ឹម** នាយកប្រតិបត្តិអង្គការ ដ្រាក / លេខទូរស័ព្ទ ០១២ ៣៧៦ ៣០១